**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ:០០៤.......សហវ.....

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លិខិតចូល
ថ្ងៃទី ១៥ ខែ ១១ ឆ្នាំ 2007

# សារាចរណែនាំ

## ស្តីពី

## ការអនុវត្តន៍ពន្ធប៉ាតង់

អនុលោមតាមខ្លឹមសារក្រឹត្យច្បាប់លេខ ២២ ក្រ.ច ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ១៩៨៥ ស្តីពីពន្ធប៉ាតង់ និងមាត្រា ៣៩ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១ន.ស.៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ ដើម្បីសំរួលដល់ការគ្រប់គ្រងរបស់រដ្ឋបាលសារពើពន្ធ ក៏ដូចជាការបំពេញបន្ថែមការយល់ដឹងរបស់អ្នកជាប់ពន្ធក្នុងគោលបំណងបង្កើនចំណូលពន្ធ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចខាងក្រោម:

១- ពន្ធប៉ាតង់ជាពន្ធប្រចាំឆ្នាំ (១ឆ្នាំប្រមូល១ដង) ត្រូវចាប់ផ្តើមប្រមូល និងប្រមូលឱ្យអស់ នៅដើមឆ្នាំយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣១ ខែ មីនា នៃឆ្នាំនីមួយៗ ។ ពន្ធប៉ាតង់ ត្រូវបង់នៅរដ្ឋបាលសារពើពន្ធដែលអ្នកជាប់ពន្ធមានទីកន្លែងប្រកបអាជីវកម្មពិតប្រាកដ ។

២- អាជីវកម្មដ្ឋាន ដែលប្រកបមុខរបរច្រើនប្រភេទ ត្រូវបង់ពន្ធប៉ាតង់ផ្សេងៗគ្នា ទៅតាមប្រភេទមុខរបរនីមួយៗ ។ ប័ណ្ណប៉ាតង់មួយ សំរាប់មុខរបរមួយ ។

៣- អាជីវកម្មដ្ឋាន ដែលមានសាខានៅតាមខេត្ត-ក្រុងតែមួយ ដែលរួមគ្នាលក់ដូរ ឬផលិតមុខទំនិញដូចគ្នា មិនចាំបាច់បង់ពន្ធប៉ាតង់ផ្សេងគ្នាទេ។ ប្រសិនបើអាជីវកម្មដ្ឋាន ដែលមានសាខានៅតាមខេត្ត-ក្រុងផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់ នៅខេត្ត-ក្រុងដែលសាខានោះស្ថិតនៅ ។

៤- ប័ណ្ណប៉ាតង់មានតំលៃតែចំពោះអ្នកដែលមានឈ្មោះក្នុងប័ណ្ណប៉ាតង់តែប៉ុណ្ណោះ ។ ករណីមានការផ្លាស់ប្តូរទីកន្លែងទៅខេត្ត-ក្រុងផ្សេង ឬ ផ្លាស់ប្តូរមុខរបរអាជីវកម្មថ្មី ត្រូវបង់ពន្ធប៉ាតង់ជាថ្មីម្តងទៀត ។

៥- អ្នកជាប់ពន្ធដែលចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃ អាចប្រើប្រាស់នូវប័ណ្ណប៉ាតង់ដែលខ្លួនបានបង់ពន្ធរួចហើយ ដើម្បីបំពេញបែបបទចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃ តែប័ណ្ណប៉ាតង់នោះត្រូវតែ

-ML.

មានមុខរបរឱ្យស្របគ្នានឹងមុខរបរដែលត្រូវចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់ថ្លៃ (ឧទាហរណ៍ : សាងសង់ លក់សំភារៈបរិក្ខារការិយាល័យ លក់គ្រឿងឧបភោគបរិភោគ រោងពុម្ព.........)។ ក្រោយពេលដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់ថ្លៃបាន អ្នកជាប់ពន្ធត្រូវបង់ពន្ធប៉ាតង់ជាថ្មីផ្អែកតាមផលរបរដែលដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់ថ្លៃបាននោះនៅតាមសាខាពន្ធដារខេត្ត-ក្រុងដែលដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់ថ្លៃបាន ដើម្បីអនុវត្តគំរោងរបស់ខ្លួន ÷

ករណីទី១- អ្នកជាប់ពន្ធដែលនៅខេត្ត-ក្រុងផ្សេង ពីខេត្ត-ក្រុងដែលដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់ថ្លៃបាន : ចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស(របបពិត) និងអ្នកជាប់ពន្ធតាមរបបម៉ៅការ គឺត្រូវមានកាតព្វកិច្ចបង់ពន្ធប៉ាតង់ជាថ្មីម្តងទៀតទៅតាមផលរបរដែលដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់ថ្លៃបាន នៅតាមសាខាពន្ធដារខេត្ត-ក្រុងដែលដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់ថ្លៃបាននោះ។ដើម្បីបង់ពន្ធប៉ាតង់ថ្មីជូន សាខាពន្ធដារតម្រូវឱ្យអ្នកជាប់ពន្ធភ្ជាប់នូវប័ណ្ណប៉ាតង់ដែលបានដាក់នៅពេលចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់ថ្លៃ ដើម្បីជាមូលដ្ឋានក្នុងការធ្វើប័ណ្ណប៉ាតង់ថ្មីជូន។ ក្នុងករណីអ្នកជាប់ពន្ធដដែលនោះដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់ថ្លៃបាននៅច្រើនកន្លែងក្នុងខេត្ត-ក្រុងតែមួយលើមុខរបរដូចគ្នា ទឹកប្រាក់ពន្ធប៉ាតង់ដែលត្រូវបង់ជាបន្តបន្ទាប់សំរាប់ខេត្ត-ក្រុងនោះ គឺមិនត្រូវឱ្យលើសពី ១,១៤០,០០០រៀលឡើយ នៅក្នុងឆ្នាំតែមួយ ។ អ្នកជាប់ពន្ធអាចប្រើប្រាស់នូវប័ណ្ណប៉ាតង់នោះ សំរាប់ភ្ជាប់ក្នុងសំណុំឯកសារបើកប្រាក់នៅរតនាគារជាបន្តទៀត ។ ចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស(របបពិត) ទោះបីទឹកប្រាក់ដែលដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់ថ្លៃបានក្នុងកំរិតណាក៏ដោយ ក៏ត្រូវតែរក្សាអត្តសញ្ញាណជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដដែលនៅក្នុងប័ណ្ណប៉ាតង់ជាបន្តបន្ទាប់ ។

ករណីទី២- អ្នកជាប់ពន្ធស្ថិតនៅក្នុងខេត្ត-ក្រុងដែលដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់ថ្លៃបាន : នៅក្នុងឆ្នាំដែលដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់ថ្លៃបាន ប្រសិនបើអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ឬអ្នកជាប់ពន្ធតាមរបបម៉ៅការ បានបង់ពន្ធប៉ាតង់ត្រូវគ្នានឹងមុខរបរដែលបានចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់ថ្លៃ ចំនួន ១,១៤០,០០០រៀល ហើយនោះ មិនតម្រូវឱ្យបង់ពន្ធប៉ាតង់ទៀតទេ ។ ប័ណ្ណប៉ាតង់ដែលបានដាក់ចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់ថ្លៃ ដែលមានទឹកប្រាក់ពន្ធប៉ាតង់ខាងលើនេះ សំរាប់ភ្ជាប់នឹងសំណុំឯកសារបើកប្រាក់នៅរតនាគារ។ ករណីទឹកប្រាក់ពន្ធប៉ាតង់ដែលបានបង់រួចមានចំនួនតិចជាង ១,១៤០,០០០រៀល អ្នកជាប់ពន្ធត្រូវបង់ពន្ធថែមនៅការិយាល័យ ឬសាខាពន្ធដារដែលគ្រប់គ្រងអ្នកជាប់ពន្ធនោះ ដោយផ្អែកតាមផលរបរដែលកើតមានជាបន្តបន្ទាប់នៅក្នុងឆ្នាំតែមួយ ប៉ុន្តែមិនឱ្យលើសពីចំនួនខាងលើនេះឡើយ ។

៦- អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចបង់ប្រាក់ពន្ធឱ្យបានត្រឹមត្រូវទៅតាមពេលវេលាដែលបានកំណត់ ។ ក្នុងករណីមិនបានបង់ឬព្យាយាមគេចវេសពីការបង់ប្រាក់ពន្ធប៉ាតង់ ឬមានការក្លែងបន្លំប័ណ្ណប៉ាតង់ នឹងត្រូវទទួលរងនូវទោសទណ្ឌដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីសារពើពន្ធ ។ អ្នកជាប់ពន្ធត្រូវដាក់តាំងឬព្យួរប័ណ្ណប៉ាតង់ នៅទីកន្លែងប្រកបអាជីវកម្មជាគោលដើមរបស់ខ្លួន ។

៧- លិខិតលេខ ៧១១ ពដ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០២ និងលិខិតលេខ ១៨៥០ ពដ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០០៥ និងលិខិតលេខ ១៩៥៥ ពដ ចុះថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០០៥ របស់នាយកដ្ឋានពន្ធដារ ត្រូវទុកជានិរាករណ៍ ។

ទទួលបានសារាចរណែនាំនេះ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពន្ធដារ គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចាត់ចែងអនុវត្តអោយទទួលបាននូវប្រសិទ្ធភាពខ្ពស់ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

<u>ចំលងជូន</u> :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- សាលាខេត្ត-ក្រុង
- គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សាខាពន្ធដារខេត្ត-ក្រុង
- ឯកសារ - កាលប្បវត្តិ